# ធម្មទេសនារបស់លោកអភិបាលអូលីវីយេ
# អភិបូជាខួប៧ឆ្នាំជាអភិបាលនៅផ្សារតូច
# ថ្ងៃទី១៩ មីនា ២០១៧

អត្ថបទទី១៖ សរ ១៧,៣-៧
អត្ថបទទី២៖ រ៉ូ ៥,១-២.៥-៨
ដំណឹងល្អ៖ យហ ៤,៥-៤២

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះនៅពេលព្រះយេស៊ូជួបជាមួយស្ត្រីសាសន៍សាម៉ារី ក្រោយមកស្ត្រីសាសន៍សាម៉ារីនោះបានទៅភូមិវិញហើយបានប្រកាសអំពីព្រះយេស៊ូ ដើម្បីឲ្យអ្នកភូមិទាំងអស់ស្តាប់លឺគាត់បានជួបជាមួយព្រះយេស៊ូ ហើយព្រះអង្គបានយល់ចិត្តគាត់ណែនាំឲ្យគាត់ទៅជាមនុស្សថ្មី។ ថ្ងៃនេះ យើងបានស្តាប់រឿងមួយយ៉ាងពិសេស ណែនាំឲ្យស្ត្រីសាម៉ារីដែលបានជួបជាមួយព្រះយេស៊ូទៅជាមនុស្សថ្មី។ ប៉ុន្មានអាទិត្យមុន យើងមានជំហានទីពីរ១២៨នាក់ខ្ញុំបានសួរគេក្នុងពេលដែលណែនាំសំណាក់ធមិថា សូមនឹកឃើញដល់ថ្ងៃដែលបានជួបជាមួយព្រះយេស៊ូដំបូងដូចស្ត្រីសាម៉ារី។ បន្ទាប់ពីគាត់បានជួបជាមួយព្រះយេស៊ូ បាននិយាយជាមួយព្រះយេស៊ូរហូតគាត់យល់ថា ព្រះយេស៊ូជាព្រះសង្គ្រោះ ព្រះយេស៊ូជាជីវិតថ្មីសម្រាប់គាត់ គាត់យល់ថាតាមពិតព្រះយេស៊ូមិនបានប្រទានទឹកមួយកែវឲ្យគាត់ ប៉ុន្តែព្រះអង្គប្រទានទឹកដែលណែនាំឲ្យជីវិតរបស់គាត់ទៅជាជីវិតថ្មី។ ស្ត្រីសាម៉ារី ជាស្ត្រីម្នាក់ដែលមានបញ្ហាច្រើននៅក្នុងជីវិតរបស់គាត់ ដោយបានទៅយកទឹកនៅពេលថ្ងៃត្រ ង់ព្រោះម៉ោងនេះគ្មានមនុស្ស គាត់ចង់លាក់ខ្លួនដោយារគាត់មិនចង់ជួបជាមួយមនុស្សឯទៀតៗ។ តែពេលជួបជាមួយព្រះយេស៊ូ គាត់លែងខ្លាចអស់ហើយគាត់បានរត់នៅភូមិគាត់ ដើម្បីប្រកាសថាពិតមែនខ្ញុំបានជួបជាមួយព្រះគ្រីស្ត ព្រះអង្គយល់ចិត្តខ្ញុំណែនាំឲ្យខ្ញុំមានជីវិតថ្មី។ យើងត្រូវតែនឹកឃើញដល់ដំណើរជីវិតរបស់យើង ជីវិតរបស់យើងបីដូចជាផ្លូវមួយដែលថ្ងៃណាមួយយើងបានជួបជាមួយព្រះជាម្ចាស់ សម្រាប់បងប្អូនដែលត្រៀមខ្លួនទទួលអគ្គសញ្ញាជ្រមុជទឹក សម្រាប់មេក្រុមយុវជន សម្រាប់ប្រធានការិយាល័យនីមួយៗនៅក្នុងភូមិភាគ សម្រាប់បងប្អូនជាគ្រីស្តបរិស័ទទាំងអស់ សម្រាប់លោកបូជាចារ្យ សម្រាប់បងប្រុសបងស្រី យើងត្រូវតែនឹកឃើញអំពីដំណើរជីវិតរបស់យើង អំពីរបៀបដែលព្រះយេស៊ូបានធ្វើដំណើរជាមួយយើង។ ផ្លូវនៃជីវិតរបស់យើងមិនមែនជាផ្លូវដែលត្រង់ទេ ជាផ្លូវដែលជួនកាលឡើងជួនកាលចុះ ជួនកាលជាផ្លូវមួយដែលមានគ្រលុកយ៉ាងច្រើន ជួនកាលជាផ្លូវមួយដែល

ណែនាំឲ្យយើងសប្បាយមែនទែន ជាផ្លូវដែលណែនាំឲ្យយើងធ្វើដំណើរជាមួយព្រះយេស៊ូ ដោយដឹងថាព្រះអង្គគង់នៅជាមួយយើងជានិច្ចនៅលើផ្លូវនៃជីវិតរបស់យើង។ ពេលយើងកំពុងរអិល កំពុងដួល យើងដឹងថាព្រះយេស៊ូលើកយើងដើម្បីឲ្យយើងទៅមុខបាន។ ថ្ងៃនេះព្រះយេស៊ូមានព្រះបន្ទូលដល់យើង ដូចស្ត្រីសាម៉ារីពីដើមថា **"ខ្ញុំសុំទឹកទទួលទានបន្តិច"** មិនមែនយើងដែលទៅសុំទឹកពីព្រះយេស៊ូ គឺព្រះអង្គជាអ្នកសុំទឹកពីយើងតែម្តង។ ព្រះយេស៊ូបន្ថែមថា **"ប្រសិនបើនាងស្គាល់ព្រះអំណោយទានរបស់ព្រះជាម្ចាស់ និងស្គាល់អ្នកដែលនិយាយទៅកាន់នាងថា ខ្ញុំសុំទឹកទទួលទានបន្តិច នោះនាងមុខជាសុំទឹកពិលោកវិញពុំខាន"** អំណោយទានដែលព្រះយេស៊ូប្រទានឲ្យយើង ណែនាំឲ្យជីវិតរបស់យើងទៅជាជីវិតថ្មី។ ខ្ញុំបានណែនាំបងប្អូននៅតាកែវច្រើនដើម្បីទទួលអគ្គសញ្ញាជ្រមុជទឹក ដើម្បីទទួលទឹកដូចព្រះយេស៊ូចង់ឲ្យទឹក។ ជាជីវិតរបស់យើងជាបូជាចារ្យ ជាអភិបាល ឲ្យយើងយកចិត្តទុកដាក់ដើម្បីស្តាប់សេចក្តីត្រូវការរបស់បងប្អូននៅជុំវិញយើង ណែនាំឲ្យបងប្អូនអាចមានជីវិតអាចសម្រុះសម្រួលបញ្ហាពិតមែន មានសេចក្តីសុខសាន្តទាំងផ្លូវចិត្ត ទាំងផ្លូវវិញ្ញាណ ដោយសារព្រះយេស៊ូយាងមក ដើម្បីណែនាំឲ្យយើងមានសុភមង្គលយ៉ាងពិតប្រាកដ។ គ្រប់ទីកន្លែងមានព្រះយេស៊ូដែលកំពុងអង្គុយទន្ទឹងរងចាំយើង ដើម្បីទន្ទឹងរងចាំមនុស្សទាំងអស់ដែលស្រេកទឹក។ ដូចស្ត្រីសាម៉ារី គាត់ស្រេកទឹកដោយសារក្នុងជីវិតគាត់មានបញ្ហាច្រើន ពេលគាត់ជួបព្រះយេស៊ូណែនាំឲ្យគាត់រកឃើញជីវិតរបស់គាត់ ដោយសារព្រះយេស៊ូយាងមកដើម្បីណែនាំឲ្យជីវិតរបស់គាត់ក្លាយទៅជាជីវិតថ្មី។ ប៉ុន្តែមិនមែនជាជីវិតថ្មីអស្ចារ្យ គាត់រស់នៅក្នុងភូមិដដែល តែគ្រប់ចំណងជើងចំណងដៃដែលជាឧបសគ្គនៅក្នុងជីវិតរបស់គាត់ដោះចេញអស់ហើយ ណែនាំឲ្យគាត់មានសេចក្តីក្លាហាន លែងខ្លាចគេមើលងាយគាត់ដោយសារគាត់បានជួបជាមួយព្រះយេស៊ូផ្ទាល់។ ក្នុងភូមិភាគភ្នំពេញរបស់យើងមានមនុស្សយ៉ាងច្រើនដែលទន្ទឹងរងចាំទឹកមួយយ៉ាងពិសេស ដើម្បីណែនាំជីវិតរបស់គេទៅជាជីវិតថ្មី។

ព្រះយេស៊ូត្រូវការយើង ដើម្បីទៅគ្រប់ទីកន្លែង ថ្ងៃនេះយើងមានការិយាល័យភូមិភាគមួយចំនួនដូចជា ការិយាល័យយុវជន មានលោក ផុន សុផល ជាប្រធាន ការិយាល័យសិក្សាអប់រំកាតូលិកភូមិភាគភ្នំពេញ មានលោកស្រី ឡៃ មករា ជាប្រធាន ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិកកម្ពុជា មានលោក លី សុវណ្ណា ជាប្រធាន ការិយាល័យសុខ

ភាព មានលោកគ្រូពេទ្យ ជួង សារឿន និងអ្នកគ្រូពេទ្យ ចិន្តា ជាប្រធាន ការិយាល័យកម្មករ មានកញ្ញា ស្រីកែវ ជាដំណាង ការិយាល័យសហគ្រិនសង្គម មានលោក សុជាតិ ជាប្រធាន ការិយាល័យអប់រំជំនឿ មានលោកគ្រូ ដួង សារង្សី ជាប្រធាន ការិយាល័យព្រះគម្ពីរ មាន លោក បញ្ញា ជាប្រធាន ការិយាល័យពិធីបុណ្យនិងសិល្បៈ ការិយាល័យលោកអភិបាល មានលោក ហៀម ចន្នី ជាប្រធាន មណ្ឌលភ្នំពេញថ្មីក្រុមអ្នកស្វាគមន៍ មានលោក អន វិចិត្រ ជាប្រធាន។ ទាំងអស់នេះ ជាកម្លាំងពិសេសនៅក្នុងភូមិភាគភ្នំពេញរបស់យើង អាចណែនាំ ឲ្យភូមិភាគភ្នំពេញមានជីវិត ដោយសារយើងចេះសហការគ្នា ជាមួយលោកបូជាចារ្យ ជា មួយបងប្រុសបងស្រី ជាមួយគ្រីស្តបរិស័ទ យើងមាន៩៥កន្លែងកន្លែងក្នុងភូមិភាគ។ ប៉ុន្មាន ខែ មុនខ្ញុំបានជួបជាមួយសម្តេចប៉ាប ខ្ញុំបានបង្ហាញអំពីការងារតាមការិយាល័យនីមួយៗ អំពីរបៀបដែលការិយាល័យនីមួយៗ ជួយផ្តល់ជីវិតឲ្យព្រះសហគមន៍គ្រប់ទីកន្លែង។ ផ្លែនៃ ជីវិតនេះយើងឃើញជាក់ស្តែង គឺបងប្អូនដែលនឹងទទួលអគ្គសញ្ញាជ្រមុចទឹកនៅរាត្រីបុណ្យ ចម្លងខាងមុខនេះ។ ព្រះសហគមន៍របស់យើងមានជីវិត តាមរបៀបដែលយើងសួរសុខទុក្ខ តាមរបៀបដែលយើងផ្តល់សក្ខីភាព ណែនាំឲ្យមនុស្សជាច្រើនអាចស្តាប់ព្រះបន្ទូលរបស់ ព្រះយេស៊ូ ប្រសិនបើស្គាល់ព្រះអំណោយទានរបស់ព្រះអង្គយើងមានជីវិតថ្មី។ យើងមិនតែ ប្រកាសអំពីព្រះបន្ទូលរបស់ព្រះយេស៊ូ មិនមែនតែមើលអំពីសេចក្តីត្រូវការតែប៉ុណ្ណឹង ប៉ុន្តែ ដើម្បីឲ្យបេសកកម្មរបស់យើងមានផ្លែនិងមានកម្លាំងច្រើន យើងស្តាប់ព្រះបន្ទូលរបស់ព្រះ យេស៊ូថែមទៀត **អ្នកថ្វាយបង្គំដ៏ពិតប្រាកដ នឹងថ្វាយបង្គំព្រះបិតាតាមវិញ្ញាណ និងតាមសេច ក្តីពិត ខ្ញុំនេះហើយ គឺខ្ញុំដែលកំពុងតែនិយាយជាមួយនាងជាព្រះគ្រីស្ត ជាព្រះអម្ចាស់ ដែល យាងមកដើម្បីសង្គ្រោះមនុស្សលោក។** តាមការិយាល័យនីមួយៗ តាមព្រះសហគមន៍ នីមួយៗអាចទៅមុខបាន ប្រសិនបើយើងថ្វាយបង្គំដល់ព្រះយេស៊ូគ្រីស្តនៅក្នុងវិញ្ញាណនិង នៅក្នុងសេចក្តីពិត។

ក្នុងវិញ្ញាណ គឺជីវិតរបស់យើងរកឃើញប្រភពនៅក្នុងព្រះយេស៊ូ ជាពិសេសនៅក្នុងរ ដូវ៤០ថ្ងៃនេះ ជាឱកាសមួយដើម្បីគិតធ្វើដូចម្តេចឲ្យយើងជាប់ជាមួយព្រះយេស៊ូនៅក្នុងការ អធិដ្ឋាន ក្នុងការស្តាប់ព្រះបន្ទូលរបស់ព្រះយេស៊ូ។ ការិយាល័យនីមួយៗត្រូវតែគតិ ព្រះ សហគមន៍នីមួយៗត្រូវតែគតិ ធ្វើដូចម្តេចដើម្បីឲ្យព្រះបន្ទូលរបស់ព្រះជាម្ចាស់នៅក្នុងជីវិត យើង និងឲ្យយើងរស់នៅតាមព្រះបន្ទូលនេះ។ ម្សិលមិញ មេក្រុមយុវជនបានពេលវេលា

មួយម៉ោងដើម្បីអានគម្ពីរនឹងគិតដោយអធិដ្ឋានផង ដែលណែនាំឲ្យគេសប្បាយចិត្ត។ យើងត្រូវការចិញ្ចឹមជីវិតរបស់យើងដោយព្រះបន្ទូលរបស់ព្រះយេស៊ូ យើងបានស្តាប់នៅពេលព្រះយេស៊ូទទួលការល្បួងពីមារសាតាំង ខ្ញុំរស់នៅដោយព្រះបន្ទូលរបស់ព្រះអង្គ។ សារលិខិតរបស់សម្តេចប៉ាប ដែលសរសេរសម្រាប់រដូវ៤០ថ្ងៃ **ព្រះបន្ទូលរបស់ព្រះជាម្ចាស់ជាព្រះអំណោយទានដែលយើងទទួលដើម្បីចិញ្ចឹមជីវិតរបស់យើង**។ សត្វគោមានក្រពះពីរ ខុសពីសត្វទាំងឡាយ ដើម្បីឲ្យទឹកដោះចេញគោត្រូវស៊ីចំនីចូលក្នុងក្រពះទីមួយក្រោយមកចូលនៅក្នុងក្រពះទីពីរទើបអាចផលិតទឹកដោះបាន។ ព្រះគម្ពីររបស់ព្រះជាម្ចាស់ដូចគ្នា ឲ្យចូលនៅក្នុងខ្លួនយើងយូរដើម្បីឲ្យធ្វើតែមួយជាមួយជីវិតរបស់យើង។ ធ្វើដូចម្តេច ដើម្បីឲ្យតាមកន្លែងនីមួយៗ យើងយកព្រះបន្ទូលជាអតិភាពសម្រាប់ជីវិតរបស់ខ្ញុំ។ ការិយាល័យអប់រំជំនឿនិងពិធីបុណ្យ ការិយាល័យព្រះគម្ពីរ ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិកកម្ពុជា សូមប្រជុំគ្នាម្តងជាមួយខ្ញុំ ដើម្បីឲ្យយើងគិតថែមទៀតធ្វើដូចម្តេចឲ្យគម្ពីរទៅគ្រប់ទីកន្លែងក្នុងភូមិភាគភ្នំពេញ។ នៅក្នុងភេចហ្វេសបុក Catholic Phnom Penh រាល់ថ្ងៃមានផុសវីដេអូស្តីពីព្រះបន្ទូលប្រចាំថ្ងៃដែលមានទាំងរូបភាព មានទាំងសម្លេង សូមបងប្អូនស្តាប់ អាន ព្រះបន្ទូលដើម្បីឲ្យព្រះបន្ទូលបំភ្លឺជីវិតរបស់យើងថ្ងៃនេះ។ ពេលយើងអានវាចូលនៅក្នុងខ្លួនរបស់យើងឲ្យយើងអនុវត្តតាម ធ្វើយ៉ាងដូចម្តេចដើម្បីឲ្យគម្ពីរទៅជាជីវិតរបស់យើង។ ឲ្យព្រះគម្ពីរចូលយូរនៅក្នុងខ្លួនយើង ដើម្បីឲ្យយើងមានកម្លាំងមួយយ៉ាងពិសេស។ ព្រះគម្ពីរហើយ ព្រះបន្ទូលហើយ ការអធិដ្ឋានហើយ ស្នាក់នៅជាមួយព្រះយេស៊ូហើយ មានន័យថាពិតមែនយើងគោរពតាមវិញ្ញាណ។

យើងត្រូវការគោរពតាមសេចក្តីពិតថែមទៀត ជាពេលវេលាមួយដើម្បីឲ្យយើងអនុវត្តអ្វីដែលយើងបានស្តាប់ព្រះបន្ទូល ឲ្យទៅជាជាការពិតនៅក្នុងជីវិតរបស់យើង។ នៅពេលយើងស្តាប់ព្រះបន្ទូលថា យើងជាអំបិល និងពន្លឺសម្រាប់ពិភពលោកទាំងមូល ឲ្យវាទៅជាការពិតនៅក្នុងជីវិតរបស់យើង។ ក្នុងសារលិខិតរបស់សម្តេចប៉ាប **ព្រះបន្ទូលជាព្រះអំណោយទាន និងបងប្អូនឯទៀតៗជាព្រះអំណោយទានដែរ** ទាំងអស់ដែលយើងស្តាប់នៅក្នុងផ្លូវវិញ្ញាណត្រូវការចេញសេចក្តីពិតនៅក្នុងជីវិតរបស់យើង ដោយយកចិត្តទុកដាក់យ៉ាងសកម្ម ដើម្បីប្រកាសដំណឹងល្អ។ សម្រាប់គណកម្មការទាក់ទងនឹងមេត្តាករុណានិងការអភិវឌ្ឍ មានការិយាល័យកម្មករ មានការិយាល័យសហគ្រិនសង្គម មានការិយាល័យសុខ

ភាព សម្រាប់ការិយាល័យយុវជន ដែលមានទំនាក់ទំនងជាមួយយុវជនយ៉ាងជិតស្និត សម្រាប់ការិយាល័យសិក្សា ដែលបានជួយកូនក្មេងយ៉ាងច្រើនពីមត្តេយ្យសិក្សារហូតដល់ឧត្តមសិក្សា មណ្ឌលវប្បធម៌ក្នុងភូមិភាគភ្នំពេញ ជាឱកាសមួយដើម្បីគិតធ្វើយ៉ាងណាឲ្យយើងមានកម្លាំងដល់កំពូល ក្នុងការអនុវត្តព្រះព្រះបន្ទូលរបស់ព្រះជាម្ចាស់ដែលយើងទទួលហើយ។ ឲ្យយើងទទួលព្រះបន្ទូលទុកសិន បើយើងមិនទទួលអ្វីដែលយើងអនុវត្តសុទ្ធតែជាទស្សនៈដែលមិនទាន់ច្បាស់ ដោយសារយើងមិនទាន់បានទទួលព្រះពន្លឺពីព្រះយេស៊ូផ្ទាល់។ ថ្ងៃនេះយើងអរព្រះគុណព្រះជាម្ចាស់ ដែលបានចាត់ឲ្យខ្ញុំមកប្រទេសកម្ពុជា១៨ឆ្នាំហើយ និងបានទទួលអគ្គសញ្ញាតែងតាំងជាអភិបាល៧ឆ្នាំហើយ បានណែនាំឲ្យយើងឃើញស្នាព្រះហស្តរបស់ព្រះជាម្ចាស់តាមរយៈបងប្អូនទាំងអស់ ដើម្បីបង្កើតឲ្យព្រះសហគមន៍របស់យើងមានជីវិត ដោយសារគ្រប់ទីកន្លែងតាមរយៈយើង ព្រះយេស៊ូអង្គុយទន្ទឹងរងចាំមនុស្សដែលកំពុងស្រេកទឹក ដែលកំពុងស្រេឃ្លាន ដែលកំពុងស្រេកយុត្តិធម៌។ យើងអាចជោគជ័យបានលុះត្រាតែ យើងយកចិត្តទុកដាក់ដើម្បីថ្វាយបង្គំតាមវិញ្ញាណនិងតាមសេចក្ដីពិត។

ថ្ងៃនេះយើងស្ដាប់ព្រះយេស៊ូ ដែលមានព្រះបន្ទូលដល់យើង **ខ្ញុំជាព្រះគ្រីស្ត ខ្ញុំជាសេចក្ដីពិត ខ្ញុំជាផ្លូវ ខ្ញុំជាជីវិត**។ ខ្ញុំសង្ឃឹមថាប៉ុន្មានឆ្នាំខាងមុខនេះ យើងឃើញបងប្អូនជាច្រើនមានអំណរសប្បាយនៅក្នុងខ្លួនដូចបងប្អូនដែលនឹងទទួលអគ្គសញ្ញាជ្រមុជទឹកខាងមុខនេះ ដើម្បីទៅប្រកាសអំពីព្រះយេស៊ូជាជីវិត ជាផ្លូវ ជាសេចក្ដីពិតដោយឥតមានភ័យខ្លាចអ្វីសោះ ដោយសារយើងបានជួបព្រះយេស៊ូហើយ និងព្រះយេស៊ូស្រឡាញ់ខ្ញុំ។ អាម៉ែន។